ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ១៧៥៣ សដណ

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០១៧

**ជម្រាបមក**

**ឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ ៖** ស្តីពីការធ្វើសកម្មភាពរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក។

**យោង** ៖ - ព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ក្រសួងមហាផ្ទៃសូមជម្រាប **ឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត** ជ្រាបថា ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល មានគោលបំណងការពារសិទ្ធិសេរីភាពប្រជាពលរដ្ឋខ្មែរ ក្នុងការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និងបានដាក់កាតព្វកិច្ចដល់ស្ថាប័នសាធារណៈទាំងអស់ ត្រូវតែលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីចូលរួមអភិវឌ្ឍប្រទេសជាតិលើគ្រប់វិស័យ។ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់កំណត់ មានសិទ្ធិពេញលេញក្នុងការធ្វើសកម្មភាពក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមច្បាប់ និងស្របតាមលក្ខន្តិកៈរបស់ខ្លួនដែលបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ ដោយគ្មានស្ថាប័ន ឬបុគ្គលណាមួយមករារាំង និងរំលោភបំពានបានឡើយ។ ទន្ទឹមនេះ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក៏ទទួលបានការលើកទឹកចិត្ត និងការអនុគ្រោះនានាស្របតាមច្បាប់ និងបទប្បញ្ញត្តិនានាជាធរមាន។

ដើម្បីជួយសម្របសម្រួល និងបង្កលក្ខណៈងាយស្រួលក្នុងការធ្វើសកម្មភាពរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់កំណត់ ក្រសួងមហាផ្ទៃ សូមធ្វើការណែនាំដូចខាងក្រោម៖

- សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលមានបំណងធ្វើសកម្មភាពនៅក្នុងដែនសមត្ថកិច្ចរដ្ឋបាលរាជធានី ខេត្តណាមួយ អាចជូនដំណឹងមកក្រសួងមហាផ្ទៃ អំពីការបើកសាខាសម្រាប់ប្រតិបត្តិការ ឬអនុវត្តសកម្មភាពរបស់ខ្លួននៅក្នុងរាជធានី ខេត្តនោះ ឬអាចជូនដំណឹងដោយផ្ទាល់ទៅរដ្ឋបាលរាជធានី ខេត្តនោះ ជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៣ (បី)ថ្ងៃ មុនការចាប់ផ្តើមអនុវត្តសកម្មភាពដោយភ្ជាប់មកជាមួយនូវគម្រោងសកម្មភាពរបស់ខ្លួន។ ក្នុងករណីនេះ មិនតម្រូវឲ្យរដ្ឋបាលរាជធានី ខេត្ត ឆ្លើយតបឯកភាពជាលាយលក្ខណ៍អក្សរទៅសាមីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះវិញឡើយ។ ទន្ទឹមនេះ ប្រសិនបើរដ្ឋបាលរាជធានី ខេត្ត ពិនិត្យឃើញថា ការធ្វើសកម្មភាពរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មិនបានធ្វើការជូនដំណឹង ឬការធ្វើសកម្មភាពផ្ទុយពីការជូនដំណឹង ឬការធ្វើសកម្មភាពប្រមូលផ្តុំប្រជាពលរដ្ឋចូលរួមធ្វើបាតុកម្មនានា ឬការធ្វើសកម្មភាពប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ

និងសន្តិសុខជាតិ រដ្ឋបាលរាជធានី ខេត្ត និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ មានសិទ្ធិក្នុងការបញ្ឈប់ ឬផ្អាកសកម្មភាពទាំងនោះ រួចហើយរដ្ឋបាលរាជធានី ខេត្ត ត្រូវរាយការណ៍ជូន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាបន្ទាន់។

- រដ្ឋបាលរាជធានី ខេត្ត និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវចាត់វិធានការបញ្ឈប់ជាបន្ទាន់ចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកទាំងឡាយណាដែលធ្វើសកម្មភាពដោយពុំបានចុះបញ្ជីនៅក្រសួងមហាផ្ទៃស្របតាមច្បាប់កំណត់ និងចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលត្រូវបានក្រសួងមហាផ្ទៃ សម្រេចលុបឈ្មោះចេញពីបញ្ជី ឬផ្អាកសកម្មភាព ហើយនៅតែបន្តធ្វើសកម្មភាពទៀត។ ក្នុងករណីនេះ អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការតាមផ្លូវច្បាប់ រួចហើយរាយការណ៍ជូន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ផ្សព្វផ្សាយបន្តដល់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងចាត់ចែងអនុវត្តតាមស្មារតីខាងលើនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

សូម ឯកឧត្តម លោកជំទាវ ទទួលនូវសេចក្តីរាប់អានអំពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធនាគារជាតិ នៃកម្ពុជា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"
- ឯកសារ - កាលប្បវត្តិ

សំគាល់
១.អ្នកដែលបានចុះបញ្ជីហើយ អាចអនុវត្តសកម្មភាពរបស់ខ្លួនបានដោយគ្មានការរារាំង...ឡើយ។
២.ការបើកសាខានៅរាជធានី ខេត្ត ត្រូវជូនដំណឹងទៅក្រសួងមហាផ្ទៃ ឬទៅអាជ្ញាធររាជធានី ខេត្ត នោះ(បីថ្ងៃមុនអនុវត្ត)។
៣.ត្រូវប្រុងប្រយ័ត្នសកម្មភាពប្រមូលផ្តុំប្រជាពលរដ្ឋធ្វើបាតុកម្ម ឬសកម្មភាពប៉ះពាល់សណ្តាប់ធ្នាប់សារធារណៈ...
៤.អ្នកដែលត្រូវបានសម្រេចលុបឈ្មោះចេញពីបញ្ជី ឬផ្អាកសកម្មភាព ពីក្រសួងមហាផ្ទៃ មិនត្រូវធ្វើសកម្មភាពឡើយ។
៥.សូមរំឭកថា ដើម្បីអនុវត្តឱ្យបានរលូន ត្រូវតែដាក់របាយការណ៍ប្រចាំឆ្នាំ ទៅក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមដែលអាចធ្វើទៅបាន។
11-10-2017
ពីអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា www.lac.org.kh សូមអភ័យទោសមិនទាន់ធ្វើបច្ចុប្បន្នភាពនៅឡើយទេ។